# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jun-2011, 15:27
CMS/CFO: Uch Arun

## ព័ត៌មានពិស្ដារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "ញត្តិរបស់ អៀង សារី សុំឲ្យដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿង (CASEMAP) របស់ ក.ស.ច.ស ទៅក្នុងសំណុំរឿង"

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ជនជាប់ចោទ និង មេធាវីការពារក្ដី |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម ធូ មណី | |

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | **មេធាវីការពារក្តីជនជាប់ចោទ:** |
| ពេជ អង្គ | លោក សុន អរុណ |
| Elisabeth SIMONNEAU FORT | លោក Michiel PESTMAN |
| | លោក Victor Koppe |
| | លោក អាង ឧត្តម |
| | លោក Michael G.KARNAVAS |
| | លោក ផាត់ ពៅសឺាង |
| | កញ្ញា Diana ELLIS QC |
| | លោក ស សូវាន |
| | លោក Jacques VERGÈS |

## I. សេចក្តីផ្តើម

១- នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ អៀង សារី តាមរយៈមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) បានដាក់ញត្តិមួយស្នើឱ្យដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿង (CASEMAP) របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”) ទៅក្នុងសំណុំរឿងលេខ ០០២ (“សំណើ”)[1]។ សំណើនេះផ្អែកលើទឡ្ហីករណ៍ចំនួនបី។ ទីមួយ មេធាវីការពារក្តីអះអាងថា CaseMap គឺជាផ្នែកមួយនៃសំណុំរឿងដោយគេជឿថា ស្ថិតក្នុងនិយមន័យនៃ “កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួរ”។ ទីពីរ មេធាវីការពារក្តីតវ៉ាថា សិទ្ធិពិនិត្យមើលប្រព័ន្ធ CaseMap គឺជាការចាំបាច់ដើម្បីការពារចំពោះសិទ្ធិទទួលបាននូវពេលវេលា និងធាតុសុបករណ៍រូបវ័ន្តរបស់ អៀង សារី ដើម្បីត្រៀមរៀបចំការការពារខ្លួនគាត់ និងទីបីដោយហេតុមេធាវីការពារក្តីជឿថា អង្គជំនុំជម្រះសាលាដំបូងមានប្រព័ន្ធ CaseMap របស់ ក.ស.ច.ស នោះ គេគួរផ្តល់ឱ្យមេធាវីការពារក្តី។ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះសាលាដំបូងឱ្យច្រានចោលសំណើនេះ ដោយសារមានកង្វះខាងអង្គហេតុ និងអង្គច្បាប់។

២- ទីមួយ មិនមានការគាំទ្រផ្លូវច្បាប់ទេ មិនថាច្បាប់ អ.វ.ត.ក ច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិ សម្រាប់សេចក្តីស្នើចំពោះផលិតផលការងារផ្ទៃក្នុងរបស់អ្នកស៊ើបអង្កេត អាចត្រូវបានគេពិចារណាថា ជាផ្នែកនៃសំណុំរឿងនោះទេ។ ផ្ទុយទៅវិញ ផលិតផលការងារស៊ើបសួរ គឺស្ទើរតែជាការងារប្រកបដោយបុព្វសិទ្ធិជាទូទៅស្ថិតក្រោមច្បាប់អន្តរជាតិ និងច្បាប់បរទេស ហើយគ្មានភ័ស្តុតាងណាដែលថា ស.ច.ស បានលះបង់បុព្វសិទ្ធិនេះចោលទេ។ ការខកខានក្នុងការផ្គត់ផ្គង់ផលិតផលការងារស៊ើបសួររបស់ ស.ច.ស មិនមានអានុភាពទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌របស់អៀង សារី ទេ ដោយហេតុថាមេធាវីការពារក្តីត្រូវបានផ្តល់នូវពេលវេលា និងធាតុសុបករណ៍រូបវ័ន្ត ហួសពីគ្រប់គ្រាន់ទៅទៀត ដើម្បីចាត់ការលើភ័ស្តុតាងក្នុងសំណុំរឿង ដែលពួកគេមានសិទ្ធិពិនិត្យ។ នេះពុំមែនជាសិទ្ធិ និងក៏ពុំមានជាលទ្ធភាពអាចធ្វើបានសម្រាប់មេធាវីការពារក្តី ក្នុងការស្រាវជ្រាវពាសពេញ CaseMap របស់ ស.ច.ស ដើម្បីពិនិត្យឡើងវិញអំពីវិធីសាស្ត្រនៃកិច្ចស៊ើបសួរទេ។

[1] សំណើរបស់ អៀង សារី សុំឱ្យដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿង (CASEMAP) របស់ កសចស ទៅក្នុងសំណុំរឿង, ៣ មិថុនា ២០១១, E91, ERN 00700055 ។

## II. ប្រវត្តិ

៣- មេធាវីការពារក្តីធ្លាប់បានស្នើពីមុនមកហើយ ដើម្បីពិនិត្យ CaseMap របស់ ស.ច.ស កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០[2]។ សំណើនេះត្រូវបានបដិសេធក្នុងដីកាសម្រេចរបស់ ក.ស.ច.ស ដោយចេញនូវការព្រមានតាមវិធាន៣៨ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០[3]។ បន្ទាប់មកនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០ មេធាវីការពារក្តីបានស្នើឲ្យ ក.ស.ច.ស ផ្តល់ "តារាងនៃការវិភាគភ្ជាប់អង្គហេតុជាក់ស្តែងនិមួយៗទៅនឹងភស្តុតាងដាក់ ឬដោះបន្ទុកនិមួយៗដែលពាក់ព័ន្ធ, ធាតុផ្សំនៃឧក្រិដ្ឋកម្មនិមួយៗដែលបានចោទប្រកាន់ និងធាតុផ្សំដ៏សំខាន់និមួយៗនៃទម្រង់នៃការចូលរួមប្រព្រឹត្តិ ដែលជាផ្នែកនៃដីកាដំណោះស្រាយ"[4] និងនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០ បានស្នើឲ្យ ក.ស.ច.ស បង្ហាញអត្តសញ្ញាណសម្ភារៈភស្តុតាងដោះបន្ទុកទាំងអស់នៅក្នុងសំណុំរឿង[5]។ សំណើដំបូងនោះត្រូវបានច្រានចោលនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០[6] ហើយសំណើលើកក្រោយមិនត្រូវបានឆ្លើយតបដោយ ស.ច.ស ទេ ដោយសារតែគ្មានមូលដ្ឋានខាងផ្លូវច្បាប់[7]។

## III. អំណះអំណាង

### ក. ប្រព័ន្ធគ្រប់គ្រងសំណុំរឿង CaseMap មិនមែនជាផ្នែកនៃសំណុំរឿងទេ ហេតុដូច្នេះមិនមែនជាកម្មវត្ថុនៃការដាក់បង្ហាញទេ

៤- មេធាវីការពារក្តីតវ៉ាថា ដោយហេតុថា ពួកគេមានសិទ្ធិពិនិត្យសំណុំរឿងអនុលោមតាមវិធាន៨៦ ពួកគេក៏មានសិទ្ធិពិនិត្យ CaseMap របស់ ស.ច.ស. ដែរ ដោយពួកគេអះអាងថា វាបង្កើតបានជាផ្នែកនៃ

---

[2] សំណើសុំពិនិត្យមើលសំណុំរឿងទាំងមូល, ១២ កុម្ភៈ ២០១០, D354, ERN 00454214 ។

[3] ដីកាសម្រេចធ្វើការព្រមាន អនុលោមតាមវិធាន៣៨, ២៥ កុម្ភៈ ២០១០, D367, ERN 00478513 ។

[4] សំណើសុំតារាងវិភាគរបស់ អៀង សារី, ៣១ មីនា ២០១០, A372 ត្រង់ ERN 00492598 ។

[5] សំណើសុំកំណត់អត្តសញ្ញាណភស្តុតាងដោះបន្ទុក, ៧ មិថុនា ២០១០, A395, ERN 00531145 ។

[6] ចម្លើយតបទៅនឹងសំណើរបស់ អៀង សារី សុំឲ្យផ្តល់តារាងវិភាគភស្តុតាងដល់មេធាវីការពារក្តី, ៨ មេសា ២០១០, A372/1, ERN 00495629 ។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះទៅ អបជ ត្រូវបានបដិសេធដោយសារមិនអាចទទួលយកបាន: សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាបដិសេធរបស់ កសចស ទៅនឹងសំណើលើកទីបី សុំឲ្យផ្តល់ជូនមេធាវីការពារក្តីនូវតារាងវិភាគភស្តុតាងជាមួយនឹងដីកាដំណោះស្រាយ, ៨ មិថុនា ២០១០, A372/2/7, ERN 00527474 ។

[7] ចម្លើយតបរបស់ក្រឡាបញ្ជី ទៅនឹងសំណើរបស់សហមេធាវីការពារក្តី អៀង សារី សុំភស្តុតាងដោះបន្ទុក, ១១ មិថុនា ២០១០, A395/1, ERN 00531151 ។

សំណុំរឿង។ អំណះអំណាងនេះ មិនត្រូវបានគាំទ្រដោយនិយមន័យនៃអ្វីដែលរួមបង្កើតបានជាសំណុំរឿង នៅក្រោមវិធាន អ.វ.ត.ក ទេ ។ វិធានកំណត់និយមន័យនៃសំណុំរឿង ដូចតទៅថា "**សំណុំរឿង**" (dossier) សំដៅលើកំណត់ហេតុទាំងអស់ (procés verbaux) នៃកិច្ចស៊ើបសួរដែលបានធ្វើឡើងក្នុងដំណើរការនៃកិច្ចស៊ើបសួរបឋម ឬកិច្ចស៊ើបសួរ រួមទាំងពាក្យសុំទាំងអស់របស់គូភាគីនានា សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងឯកសារភ្ជាប់ណាមួយទៅនឹងសេចក្តីសម្រេចទាំងនោះ នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី រួមទាំងកំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះ[8]" ។

៥- ដើម្បីទាញអំណះអំណាងថា CaseMap គឺជាផ្នែកនៃសំណុំរឿង មេធាវីការពារក្តីអះអាងថាកម្មវិធីសូហ្វវែរអេឡិចត្រូនិចនេះ គឺជា "កំណត់ហេតុ" ឬ *procés verbaux* ។ ការបកស្រាយណាក៏ដោយ គេច្បាស់ណាស់ថាវាមិនមែនជាករណីដូច្នេះទេ។ ពាក្យជាភាសាអង់គ្លេស "កំណត់ហេតុនៃកិច្ចស៊ើបសួរ" គឺជាពាក្យបកប្រែពីន័យនៃពាក្យភាសាបារាំង *procés verbaux* ដែលជាពាក្យមានលក្ខណៈជាសិល្បៈ។ ពាក្យនេះមិនមែន (និង *មិនអាច*) រួមបញ្ចូលអ្វីៗគ្រប់បែបយ៉ាងដែលបានសរសេរដោយ ក.ស.ច.ស នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ ដូចដែលមេធាវីការពារក្តីអះអាងនោះទេ។ ផ្ទុយមកវិញ "កំណត់ហេតុ" ឬ *procés verbaux* គឺជាឯកសារច្បាប់ជាក់លាក់មួយដែលជា "របាយការណ៍នៃកិច្ចដំណើរការនីតិវិធីយ៉ាងភូតជាលាយលក្ខណ៍អក្សរដ៏ពិស្តារ" មួយ[9]។ នៅ អ.វ.ត.ក ឯកសារនេះផ្តល់នូវកំណត់ហេតុអំពីការងាររបស់ ស.ច.ស[10]។

៦- ច្បាប់នីតិវិធីកម្ពុជា ក៏ប្រើពាក្យក្នុងន័យដូច្នេះដែរ។ មាត្រា២៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CCPC") ចែងបញ្ជាក់ថា ការសួរចម្លើយ ការស្តាប់ចម្លើយ ឬការសួរតទល់និមួយៗ ត្រូវតែមានធ្វើកំណត់ហេតុ។ មាត្រា២៤០ ចែងអំពីទម្រង់នៃលក្ខខណ្ឌតម្រូវនៃ "កំណត់ហេតុ"[11] ដោយចែងថា "កំណត់ហេតុ" ត្រូវគេរំពឹងទុកថា ជាឯកសារតាមប្រភេទជាក់លាក់ណាមួយ មិនមែនគ្រាន់តែ

---

[8] សទ្ទានុក្រម វិធានផ្ទៃក្នុង អវតក

[9] វចនានុក្រមច្បាប់ *Black's Law Dictionary's Law Dictionary* (ច្បាប់បោះពុម្ពលើកទី៨, ឆ្នាំ២០០៤), 1243 ។

[10] វិធានផ្ទៃក្នុង អ.វ.ត.ក, វិធាន 25, 28, 50, 55, 57, 58, 59, 61, 62, 63 ។ សូមអានផងដែរទាក់ទងនឹងស្ថាប័នតុលាការ មានវិធាន 13, 71, 72, 76 ។

[11] កំណត់ហេតុ ត្រូវមាន: ឈ្មោះចៅក្រមស៊ើបសួរ, ឈ្មោះក្រឡាបញ្ជី, លេខ និងកាលបរិច្ឆេទសំណុំរឿង, កាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ប្រភេទបទល្មើសដូចបានចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងកាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ ។

ជាឯកសារណាមួយដែលបានសរសេរឡើងដោយ ស.ច.ស ឬបុគ្គលិករបស់ពួកគេប៉ុណ្ណោះទេ កុំថាឡើយដល់ទៅឃ្លាំងផ្ទុកឯកសារក្នុងកុំព្យូទ័រ និងប្រព័ន្ធវិភាគឯកសារដូចជា CaseMap នេះ។

៧- ការបកស្រាយដូច្នេះ ត្រូវបានបញ្ជាក់អះអាងតាមរយៈភាសាបារាំង ទៅតាមការយល់ទៅលើពាក្យ *procés verbaux* ជាឧបករណ៍មួយចែងថា សកម្មភាពនានាដែលបានចាត់អនុវត្តឲ្យបានសម្រេចធ្វើឡើងដោយចៅក្រមស៊ើបអង្កេត គឺពិតជាបានកើតឡើងមែន។ Pradel រៀបរាប់អំពីសកម្មភាពធ្វើបានសម្រេចដោយចៅក្រមស៊ើបអង្កេតថា ត្រូវតែមានភ័ស្តុតាងបញ្ជាក់អំពីអត្ថិភាពនៃ *procés verbaux:* ថាវត្តមានរបស់ចៅក្រមនៅទីកន្លែងឧក្រិដ្ឋកម្ម ស្តាប់សវនាការចំពោះភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី, បញ្ហារបស់អ្នកជំនាញ, ការតទល់ និងការធ្វើត្រាប់ឡើងវិញ[12] ។ Vandermeersch អះអាងបញ្ជាក់ថាមានតែធាតុផ្សំជាក់លាក់នៃកិច្ចស៊ើបសួរតែប៉ុណ្ណោះដែលត្រូវតែជាប់ទាក់ទងនឹង *procés verbaux*[13]។

៨- ច្បាស់ណាស់ថា CaseMap មិនមែនស្ថាបនាឡើង ដើម្បីជាកំណត់ហេតុនៃកិច្ចស៊ើបសួរ ឬ *procés verbaux* នៅក្រោមច្បាប់ អ.វ.ត.ក ណាមួយ ច្បាប់ជាតិ ឬច្បាប់បារាំងទេ។ ដោយសារវាមិនមែនជាឯកសារ ប៉ុន្តែជាប្រព័ន្ធមូលដ្ឋានទិន្នន័យសូហ្វវែរ ដែលមិនបានបំពេញតាមលក្ខខណ្ឌនៅក្នុងច្បាប់កម្ពុជា និងច្បាប់បរទេស និងក៏មិនអាចបកស្រាយថាជាប្រភេទឯកសារដែលគេបានរំពឹងទុកតាមនិយមន័យដែរ។

## ខ. ប្រព័ន្ធគ្រប់គ្រងសំណុំរឿង CaseMap គឺជាផលិតផលនៃការងារសម្ងាត់ ហេតុដូច្នេះមិនមែនជាកម្មវត្ថុនៃការដាក់បង្ហាញទេ

៩- ក្រៅពីជាមូលដ្ឋានទិន្នន័យកុំព្យូទ័រដូចជា CaseMap ដែលគេច្បាស់ណាស់ថាមិនរាប់បញ្ចូលនៅក្នុងនិយមន័យនៃសំណុំរឿងនេះ ករណីយុត្តិសាស្ត្រជាតិ និងអន្តរជាតិគាំទ្របន្ថែមទៀតទៅលើគោលជំហរដែលថា ផលិតផលការងារស៊ើបអង្កេត ដូច CaseMap នេះ គឺមិនដាក់បង្ហាញដល់ភាគីនានាឡើយ។ មានភាពខុសគ្នាយ៉ាងច្បាស់រវាង*ផលិតផល* នៃកិច្ចស៊ើបសួរព្រហ្មទណ្ឌ ដូចជាភ័ស្តុតាងថាតើជា

[12] Jean Pradel, *Manuel de Procédure Pénale* (ច្បាប់បោះពុម្ពលើកទី១៣, 2006/2007), §684 ។

[13] Henri-D Bosley និង Damien Vandermeersch, *Droit de la Procédure Pénale* (ច្បាប់បោះពុម្ពលើកទី២, 2001), 306 ។ សូមអានផងដែរ Michel Franchimont, Anne Jacobs និង Adrien Masset, *Manuel de procédure pénale* (ច្បាប់បោះពុម្ពលើកទី, 2006), 247–250 ។

ភស្តុតាងដោះបន្ទុក ឬដាក់បន្ទុក និងការចោទប្រកាន់ដែលគេត្រូវផ្តល់ឲ្យមេធាវីការពារក្តី និងឯកសារការងារផ្ទៃក្នុងទាក់ទងនឹងកិច្ចស៊ើបសួរដែលត្រូវការពារមិនឲ្យលាតត្រដាង។

១០- វិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៃអតីតយូហ្គោស្លាវី ("ICTY") និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា ("ICTR") ដាក់លក្ខខណ្ឌតម្រូវគ្រប់ភ័ស្តុតាងទាំងអស់ដែលនឹងត្រូវយកទៅប្រើនៅពេលសវនាការ និងភ័ស្តុតាងដោះបន្ទុកទាំងអស់ដែលត្រូវដាក់បង្ហាញ[14] ប៉ុន្តែ *ថ្លែងចំៗថា* "របាយការណ៍ អនុស្សរណៈ ឬឯកសារផ្ទៃក្នុងដទៃទៀតដែលបានរៀបចំដោយភាគីណាមួយ អ្នកជំនួយការ ឬអ្នកតំណាងរបស់ភាគីនោះ ទាក់ទិននឹងកិច្ចស៊ើបសួរ ឬការត្រៀមរៀបចំករណីនោះ មិនមែនជាកម្មវត្ថុនៃការដាក់បង្ហាញ ឬការជូនដំណឹងតាមវិធានទាំងនោះទេ"[15]។ ការណ៍នេះរួមបញ្ចូលទាំងកំណត់នៃបទសម្ភាសន៍[16], "កំណត់នៃកិច្ចស៊ើបសួរ"[17],ការផ្ទុះបញ្ចាំងអំពីផែនការរបស់សាក្សីក្នុងអម្លុងពេលសវនាការ[18], "ការអភិវឌ្ឍន៍នូវវិធីសំខាន់ៗសម្រាប់កិច្ចស៊ើបសួរ"[19], "ការវាយតម្លៃផ្ទៃក្នុងលើ...ដំណើរការងារ", "បច្ចេកទេសនៃកិច្ចស៊ើបសួរ" និង "ការសន្និដ្ឋាន និងអនុសាសន៍ដែលបានផ្តល់ដោយអ្នកស៊ើបអង្កេត"[20]។

---

[14] វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY/ICTR ("RPE"), វិធាន 66–70 ។

[15] វិធាន៧០ នៃ ICTY RPE; ចម្លងយកនៅក្នុងវិធាន៧០ នៃ ICTR RPE; វិធាន៧០ នៃវិធាន SCSL RPE; វិធាន៨១(១) នៃវិធាន ICC RPE: "ការកំហិតចំពោះការដាក់បង្ហាញ: របាយការណ៍, អនុស្សរណៈ ឬឯកសារផ្ទៃក្នុងដទៃទៀត ដែលបានរៀបចំដោយគូភាគីណាមួយ អ្នកជំនួយការ ឬអ្នកតំណាងរបស់ភាគីនោះ ទាក់ទិននឹងកិច្ចស៊ើបសួរ ឬការត្រៀមរៀបចំករណីនោះ មិនជាកម្មវត្ថុនៃការដាក់បង្ហាញទេ" ។

[16] *រដ្ឋអាជ្ញា ទល់នឹង* Eliézer *Niyitegeka*, សំណុំរឿងលេខ ICTR-96-14-T, សាលក្រម (១៦ ឧសភា ២០០៣), កថាខ័ណ្ឌ៤១ ។

[17] *រដ្ឋអាជ្ញា ទល់នឹង* Blaskic, "សេចក្តីសម្រេចលើការផលិតសម្ភារៈស្រាវជ្រាវ", សំណុំរឿងលេខ IT-95-14-PT, ២៧ មករា ១៩៩៧, កថាខ័ណ្ឌ៤០ ។

[18] *រដ្ឋអាជ្ញា ទល់នឹង* Ildephonse *Nizeyimana*, សំណុំរឿងលេខ ICTR-00-55C-PT, សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់មេធាវីការពារក្តីសុំឲ្យបង្ហាញកំណត់ហេតុមុនៗ (៣១ មករា ២០១១), កថាខ័ណ្ឌ៦ ។

[19] *រដ្ឋអាជ្ញា ទល់នឹង* Thomas *Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06, ឧបសម្ព័ន្ធ២ ទៅនឹង: សេចក្តីសម្រេចចេញឯកសារកែតម្រូវ និងលុបចេញផ្នែកខ្លះនៃ "សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំមិនឲ្យបង្ហាញអត្តសញ្ញាណបុគ្គលម្ភៃប្រាំនាក់ដែលផ្តល់ព័ត៌មានស្តីពី *គោលការណ៍ ទូហ្គួគេ (អ្នកឯងដែរ) (Tu Quoque)* ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, ២ មិថុនា ២០០៩, ឯកសារលេខ ICC-01/04-01/06-1924- ឧបសម្ព័ន្ធ២, កថាខ័ណ្ឌ៣១ ។

[20] *រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo*, សំណុំរឿងលេខ ICC-01/04-01/06, សេចក្តីសន្និដ្ឋានរបស់អយ្យការស្តីពីការដាក់បង្ហាញ អនុលោមតាមដីកាសម្រេចទី I របស់ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១០, ១៧ វិច្ឆិកា ២០១០, ឯកសារលេខ ICC-01/04-01/06-2625-Red, កថាខ័ណ្ឌ២១ ។

១១- នេះគឺកើតចេញមកពី "ទ្រឹស្តីដែលជាស្នាដៃផលិត" ឬ គោលការណ៍ស្តីពី"បុព្វសិទ្ធិនៅក្នុងរឿងក្តីវិវាទ" នៃយុត្តាធិការក្នុងស្រុកនានា ដែលមិនដាក់បញ្ចូលនៅក្នុងការបង្ហាញឲ្យដឹងនូវ "ឯកសារ និងវត្ថុប្រច័ក្ស ទាំងឡាយដែលបានត្រៀមរៀបចំទុកជាមុនសម្រាប់រឿងក្តីវិវាទ ឬសំរាប់សវនាការជំនុំជម្រះក្តីដោយភាគីម្ខាងទៀត ឬសំរាប់ភាគីម្ខាងទៀត ឬតំណាងរបស់គេ"[21]។ វិធានដែលការពារឯកសារការងារទាក់ទងនឹងការស៊ើបសួរបាន "ផ្អែកទៅលើភាពចាំបាច់ត្រូវមានតំបន់ដែលត្រូវបានការពារមួយ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការស៊ើបអង្កេត និងការត្រៀមរៀបចំសំណុំរឿងសំរាប់សវនាការ"[22]។ កំណត់ហេតុដែលបានធ្វើឡើងដោយនគរបាលនៅក្នុងពេលស៊ើបអង្កេតរបស់ពួកគេ ត្រូវបានគេដាក់បញ្ចូលយ៉ាងជាក់លាក់នៅក្នុងវិសាលភាពនៃវិធាននេះ[23]។

១២- អាស្រ័យហេតុនេះ ប្រព័ន្ធគ្រប់គ្រងឯកសារ casemap របស់ កសចស គឺជា"ឯកសារ ឬការប្រាស្រ័យទាក់ទងគ្នាដែលមានបុព្វសិទ្ធិ"មួយ[24]។ មេធាវីការពារក្តីមិនបានផ្តល់ភ័ស្តុតាងថា ប្រព័ន្ធគ្រប់គ្រងឯកសារ casemap របស់ កសចស ត្រូវបានផ្តល់ឲ្យទៅអង្គជំនុំជម្រះសាលាដំបូងនោះឡើយ ហេតុដូចនេះគ្មានភ័ស្តុតាងណាដែលបង្ហាញថា កសចស បានលះបង់ចោលនូវបុព្វសិទ្ធិរបស់ខ្លួនលើព័ត៌មានទាំងនោះទេ។ ផ្ទុយទៅវិញ កសចស មិនបានបង្ហាញឲ្យឃើញច្បាស់ពីបំណងរបស់ខ្លួនដែលថា ប្រព័ន្ធគ្រប់គ្រងឯកសារ casemap របស់ខ្លួន មិនគួរត្រូវបានចាត់ទុកថាជា "ឯកសារសំងាត់ផ្ទៃក្នុង"មួយនោះឡើយ"[25]។

## **គ. ការបង្ហាញឲ្យដឹងនូវប្រព័ន្ធគ្រប់គ្រងឯកសារ Casemap នឹងធ្វើឲ្យមានផលប៉ះពាល់ជាអវិជ្ជមាននៅលើកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ**

[21] វិធាន២៦.ខ.៣ នៃវិធានស្តីពីនីតិវិធីរដ្ឋប្បវេណីរបស់រដ្ឋសហព័ន្ធនៃ សរអ។ *សូមអានផងដែរ ករណីរឿងក្តីរបស់Anderson ទល់នឹង Bank of British Columbia(1875-76)Lr 2 ch D644, 656(James LJ), 658 (MellishLJ)* (UK); *R v Steyn* 1954 (1) SA 324 (A), 332 A–B (ប្រទេសអាហ្វ្រិកខាងត្បូង)។

[22] ករណីរឿងក្តីរបស់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ *ទល់នឹង Blank* [ឆ្នាំ២០០៦] 2 SCR 319, កថាខណ្ឌទី២៧-២៨ (ប្រទេសកាណាដា)។

[23] ករណីរឿងក្តីរបស់ *S ទល់នឹង Mavela* 1990 (1) SACR 582 (A), 590-591 (Eksteen JA)។

[24] សំណុំរឿង ញត្តិរបស់ អៀង សារី ស្នើសុំឲ្យដាក់បញ្ចូល ប្រព័ន្ធគ្រប់គ្រងឯកសារ CaseMap របស់ កសចស ទៅក្នុងសំណុំរឿង, ចុះថ្ងៃទី៣ មិថុនា ២០១១, ឯកសារលេខ E91 ត្រង់លេខ ERN 00700062 កថាខណ្ឌទី២០។

[25] សំណុំរឿង ញត្តិរបស់ អៀង សារី ស្នើសុំឲ្យដាក់បញ្ចូល ប្រព័ន្ធគ្រប់គ្រងឯកសារ CaseMap របស់ កសចស ទៅក្នុងសំណុំរឿង, ចុះថ្ងៃទី៣ មិថុនា ២០១១, ឯកសារលេខ E91 ត្រង់លេខ ERN 00700062 កថាខណ្ឌទី២០។

១៣- មេធាវីការពារក្តីបានស្នើសុំឱ្យពិនិត្យឡើងវិញចំពោះវិធីសាស្ត្រនៃការស៊ើបសួររបស់ កសចស[26] មាន ការមិនត្រឹមត្រូវទាំងស្រុង និងអាចធ្វើឱ្យមាន "ការធ្វើត្រាប់ចំអកដោយមានការមិនពេញចិត្តយ៉ាងខ្លាំង បំផុត" ចំពោះការស៊ើបសួរខាងបទព្រហ្មទណ្ឌនេះ[27]។ ការដែលបញ្ចេញឱ្យគេដឹងនូវឯកសារការងារ ផ្ទៃក្នុងរបស់ កសចស នាពេលបច្ចុប្បន្ននេះ គឺមិនបានផ្តល់នូវរូបភាពដ៏ត្រឹមត្រូវ អំពីការងារ ជារួមទាំងមូលរបស់ កសចស នោះឡើយ (រឿងនេះអាចរកមើលឃើញនៅក្នុងដីកាដំណោះស្រាយ) ដែលជាការរំលោភបំពានទៅលើការសម្ងាត់របស់ កសចស មុខជានឹងធ្វើឱ្យការវាយតម្លៃលើភស្តុតាង របស់អង្គជំនុំជម្រះសាលាដំបូង មានលក្ខណៈខុសពីសភាពដើម និងធ្វើឱ្យមានឥទ្ធិពលរារាំងដ៏គួរឱ្យ កត់សំគាល់ទៅលើការស៊ើបអង្កេតផ្សេងៗទៀត។

១៤- ការត្រៀមរៀបចំសំណុំឯកសារសំរាប់រឿងក្តី "មិនត្រូវឱ្យមានការរារាំងដោយសារលទ្ធភាពដែលថា ឯកសារដែលខ្លួនបានត្រៀមរៀបចំ អាចឱ្យយកចេញពីក្នុងសំណុំឯកសាររបស់ខ្លួនបាន ហើយបង្ហាញ ដល់តុលាការតាមរបៀបមួយដែលផ្សេងពីរបៀបដែលគេបានគ្រោងទុកជាមុន នៅក្នុងពេលដែលកំពុង ត្រៀមរៀបចំសំណុំឯកសារទាំងនេះ"[28]។ វិធានដែលប្រឆាំងនឹងការបង្ហាញឱ្យដឹងអំពីលទ្ធផលការងារ នៃការស៊ើបសួរនៅក្នុងរឿងក្តីព្រហ្មទណ្ឌ គឺតែត្រូវបានពឹងផ្អែកមិនគ្រាន់តែដោយ កសចស ប៉ុណ្ណោះទេ ថែមទាំងដោយអ្នកស៊ើបអង្កេតជាតិ និងអន្តរជាតិ និងរដ្ឋអាជ្ញានៅទូទាំងពិភពលោកផងដែរ។ វិធាន ទាំងនេះ គឺផ្អែកលើគោលការណ៍ដែលថា "ភាគីនីមួយៗគួរតែមានសេរីភាពក្នុងការត្រៀមរៀបចំសំណុំ ឯកសារសំរាប់រឿងក្តីរបស់ខ្លួនឱ្យបានពេញលេញបំផុតតាមដែលអាចធ្វើទៅបាន ដោយគ្មានហានិភ័យ ថា ភាគីបដិបក្ខរបស់ខ្លួននឹងអាចមានលទ្ធភាពបង្ហាញត្រឡប់ទៅវិញនូវឯកសារដែលកើតចេញមកពីការ ត្រៀមរៀបចំរបស់ខ្លួន"[29]។ ដើម្បីបង្កើតឱ្យទៅជាបុព្វបទមួយដែលធ្វើឱ្យខូចដល់គោលការណ៍នេះ ស្នើ

[26] ញត្តិរបស់ អៀង សារី ស្នើសុំឱ្យដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងឯកសារ CaseMap របស់ កសចស ទៅក្នុងសំណុំរឿង, ចុះថ្ងៃទី៣ មិថុនា ២០១១, ឯកសារលេខ E91 ត្រង់លេខ ERN 00700055 កថាខណ្ឌទី ២,១៤ ,១៥ ,១៦ ,១៧ ។

[27] ករណីរឿងក្តីរបស់ *Susan Hosiery Ltd ទល់នឹង រដ្ឋមន្ត្រីក្រសួងប្រាក់ចំណូលជាតិ* [1969] 2 Ex CR 27, [9] (Jackett P)។

[28] ករណីរឿងក្តីរបស់ *Susan Hosiery Ltd ទល់នឹង រដ្ឋមន្ត្រីក្រសួងប្រាក់ចំណូលជាតិ* [1969] 2 Ex CR 27, [8] (Jackett P)។

[29] ករណីរឿងក្តីរបស់ *Three Rivers District Council ទល់នឹង អភិបាល និងក្រុមហ៊ុននៃធនាគារ* the *Bank of England (No 6)* [2005] 1 AC 610 at [52]។

នឹងធ្វើឱ្យខូចដល់សមត្ថភាពរបស់អ្នកស៊ើបអង្កេតដែលត្រូវស្មោះត្រង់នៅក្នុងការគោរពការអនុវត្ត និងការតាមដានចំពោះទ្រឹស្តីនៃករណីរឿងផ្សេងៗ។

១៥- មកដល់ត្រឹមកម្រិតដែលថា ប្រព័ន្ធគ្រប់គ្រងឯកសារ Casemap អាចនឹងបង្ហាញឱ្យឃើញច្បាស់អំពីករណីដែលប្រឆាំងនឹងជនជាប់ចោទនោះ គឺព័ត៌មាននេះមាននៅក្នុងដីកាដំណោះស្រាយ ដីកាសន្និដ្ឋានស្ថាពរ និងនៅក្នុងបញ្ជីរាយឈ្មោះឯកសាររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០នៃវិធានផ្ទៃក្នុងស្រាប់រួចហើយ។ លើសពីនេះ វិធានផ្ទៃក្នុងរបស់ អវតក បានធានាថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អំពីពិរុទ្ធភាព ឬភាពស្លូតត្រង់របស់ជនជាប់ចោទគឺត្រូវបានកម្រិតត្រឹមតែតាមអង្គហេតុដូចដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងភ័ស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ។ ការបើកឱ្យគ្រប់ភាគីទាំងអស់ ក៏ដូចជាស្ថាប័ននានារបស់តុលាការ អាចចូលពិនិត្យមើលឯកសារការងារនានារបស់ កសចស បាន គឺមានន័យថា ភ័ស្តុតាងនានាដែលនៅក្នុងសំណុំរឿងអាចនឹងមានស្នាមប្រឡាក់ដោយសារទម្ងន់ដែល កសចស បានផ្តល់ទៅឱ្យ ហើយមិនមែនទើបតែត្រូវបានវាយតម្លៃថ្មីៗនេះទេ។

## គ. ការសម្ងាត់នៃប្រព័ន្ធគ្រប់គ្រងឯកសារ Casemap របស់ កសចស គឺមិនជ្រៀតជ្រែកដល់សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវរបស់ អៀង សារី ឡើយ

១៦- មេធាវីការពារក្តីបានលើកតវ៉ាថា បន្ទុកក្នុងការពិនិត្យឡើងវិញលើឯកសារនីមួយៗនៅក្នុងសំណុំរឿង *ចាប់តាំងពីដំបូងមក* គឺវាធំធេងពេក ហើយការដែលបញ្ចេញឱ្យគេដឹងអំពីការងាររបស់ កសចស នឹងជួយឱ្យចំណេញពេលដល់មេធាវីការពារក្តី និងជួយឱ្យពួកគេអាចយល់ពីរឿងក្តី។ នេះគឺមិនមែនជាការពិតនោះទេ។ មេធាវីការពារក្តីមានពេលវេលាជាងបីឆ្នាំកន្លះឯណោះសំរាប់ពិនិត្យមើលឯកសារនានាឡើងវិញ និងសំរាប់ធ្វើការវាយតម្លៃជាប្រចាំ។ ពួកគេមិនគ្រាន់តែត្រូវបានផ្តល់ពេលវេលាគ្រប់គ្រាន់នៅមុនពេលសវនាការចាប់ផ្តើមតែប៉ុណ្ណោះទេ ក៏ប៉ុន្តែពួកគេថែមទាំងមានផាសុបករណ៍ជាអេឡិចត្រូនិចសម្រាប់ទុកឱ្យពួកគេវាយតម្លៃលើភ័ស្តុតាង ទាំងសំរាប់ភ័ស្តុតាងនីមួយៗ និងទាំងនៅក្នុងបរិបទនៃគ្រប់ភ័ស្តុតាងទាំងអស់ទៀតផង។ សំណុំរឿងត្រូវបានផ្តល់ទៅឱ្យមេធាវីការពារក្តីជាទម្រង់អេឡិចត្រូនិចតាមរយៈប្រព័ន្ធគ្រប់គ្រងឯកសារ Zylab។ ឯកសារអាចពាក់ព័ន្ធផ្សេងទៀត ត្រូវបានផ្តល់ឱ្យនៅក្នុងឃ្លាំង

ផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ Zylab ដើម្បីជួយដល់មេធាវីការពារក្តី នៅក្នុងការត្រៀមរៀបចំសំណុំឯកសាររឿងក្តីរបស់ខ្លួន។

១៧- សិទ្ធិក្នុងការពិនិត្យមើលសំណុំរឿងនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ ត្រូវបានផ្តល់ជូនជាទម្រង់អេឡិចត្រូនិចដែលអាចឲ្យស្វែងរកបានមួយដែលមេធាវីការពារក្តី មានគ្រប់រាល់ឱកាសដើម្បីត្រៀមរៀបចំសំណុំឯកសារសំរាប់រឿងក្តី តាមវិធីជាច្រើន ដើម្បីជួយឲ្យមានលទ្ធភាពអាចធ្វើវិភាគលើភ័ស្តុតាងបានដោយប្រសិទ្ធភាព។ មេធាវីការពារក្តីមានទទួលផងដែរនូវកម្មវិធី CaseMap ផ្ទាល់ខ្លួន ដើម្បីជួយនៅក្នុងដំណើរការនេះ។ ជាងនេះទៀត មេធាវីការពារក្តីបានទទួលឯកសារជាង១០០០ ដែលគាំទ្រដល់ការសេចក្តីផ្តើមនៃការសន្និដ្ឋាននៃឯកសារនៅក្នុងទម្រង់ CaseMap ថាជាឯកសារមិនផ្លូវការមួយ។ ឯកសារនេះ មានដាក់បញ្ចូលឯកសារជាង១០០០ ដែលឯកសារនីមួយៗបានដាក់ភ្ជាប់ និងបានរៀបរាប់នៅក្នុងប្រភេទពាក់ព័ន្ធ ដើម្បីឲ្យមេធាវីការពារក្តីជាមុន ក្នុងការចាប់ផ្តើមរៀបចំសំណុំរឿង។

១៨- រាល់ធាសុបករណ៍ទាំងអស់នេះ ត្រូវបានផ្តល់ជូនពួកគេនៅក្នុងពេលដ៏ខ្លីបន្ទាប់ពីជនជាប់ចោទ ត្រូវបានចាប់ខ្លួនដែលមានរយៈពេលបីឆ្នាំកន្លះមកហើយ។ ជាងនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើបញ្ហានេះ ដោយបញ្ជាក់ថា បន្ទាប់ពីបានចូលមើលឯកសារនៅក្នុងសំណុំរឿង ចាប់តាំងពីចាប់ផ្តើមការស៊ើបសួរ *[មេធាវីការពារក្តី]* មិនអាចប្រកាសថាកង្វះពេលវេលា និងធាសុបករណ៍គ្រប់គ្រាន់ សំរាប់ការត្រៀមរៀបចំការការពារក្តីរបស់ខ្លួនឡើយ[30]។

១៩- សិទ្ធិរបស់ជនជាប់ចោទណាម្នាក់ក្នុងការទទួលបាននូវពេលវេលា និងធាសុបករណ៍គ្រប់គ្រាន់ សំរាប់ការត្រៀមរៀបចំការការពារក្តីរបស់ខ្លួន គឺជាសិទ្ធិជាមូលដ្ឋានដែលត្រូវតែគោរព។ ក៏ប៉ុន្តែនេះគឺជាបញ្ហាដែលត្រូវជ្រើសរើសថា តើជនជាប់ចោទ និងមេធាវីរបស់គេ បានប្រើប្រាស់ពេលវេលានោះនិងធាសុបករណ៍ទាំងនោះដែរ ឬក៏អត់។ អង្គជំនុំជម្រះសាលាដំបូងមិនអាចបង្ខំមេធាវីទាំងនោះ ឲ្យធ្វើដូច្នេះ

[30] សូមអាន ការសំរេចបញ្ចប់របស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំបន្ថែមពេលវេលាឯកសារលេខ (E9/7 និងលេខ E9/4/9),ចុះថ្ងៃទី ២៨ កុម្ភៈ ឆ្នាំ២០១១ ឯកសារលេខ E9/7/1, ERN 00648637។ ដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើ សំណើសុំបន្ថែមពេលវេលាក្នុងការដាក់បញ្ជីរាយឈ្មោះឯកសារ និងវត្ថុតាង, ចុះថ្ងៃទី ២៩ មិនា ២០១១, ឯកសារលេខ E9/16/4, ERN 00657167, ដោយកត់សំគាល់ថា មេធាវីការពារក្តី, "ដោយបានទទួលនូវការបើកសិទ្ធិឲ្យចូលពិនិត្យមើលសំណុំរឿង ចាប់តាំងពីពេលចាប់ផ្តើមកិច្ចស៊ើបសួររបស់តុលាការមកនោះ មិនអាចទាមទារថា គ្មានពេលវេលា និងធាសុបករណ៍គ្រប់គ្រាន់សំរាប់ការត្រៀមរៀបចំការការពារក្តីរបស់ខ្លួនបានឡើយ"។

បានឡើយ[31]។ ស្រដៀងគ្នានេះដែរ គឺមិនមែនជាកាតព្វកិច្ចរបស់ កសចស អង្គជំនុំជម្រះសាលាដំបូង ឬរបស់ភាគីណាមួយផ្សេងទៀត នៅក្នុងរឿងត្រៀមរៀបចំការពារក្ដីពិតប្រាកដ មេធាវីការពារក្ដីរបស់ អៀង សារី ដោយផ្ដល់ទៅឱ្យពួកគេនូវគ្រប់រាល់ផលិតផលការងារទាំងអស់ដែលជាការសម្ងាត់របស់ខ្លួន ទោះបីជាក្នុងទម្រង់ជាប្រព័ន្ធគ្រប់គ្រងឯកសារ Casemap ឬជាកម្មវិធីផ្នែករឹងនៃកំព្យូទ័រក៏ដោយ, ជាកំណត់ហេតុប្រជុំផ្សេងៗ ឬជាឯកសារផ្ទៃក្នុងណាមួយផ្សេងទៀតរបស់ខ្លួនក៏ដោយ។ ជំហរដែលមិនអាចឃាត់ឃាំងបានរបស់មេធាវី អាចនឹងផ្ទុយគ្នាពីភាគីដទៃៗទៀត ចំពោះករណី តើអ្នកណាដែលជាអ្នកមានលទ្ធភាពធ្វើវិភាគលើរឿងក្ដីដោយខ្លួនឯងផ្ទាល់ ដោយមិនចាំបាច់មានជំនួយពីសហចៅក្រមស៊ើបអង្កេត តាមរយៈប្រព័ន្ធសម្រាប់វិភាគព័ត៌មានរបស់ខ្លួន ប្រព័ន្ធគ្រប់គ្រងឯកសារ Casemap។

## IV. អំពីសំណងជួសជុលដែលបានស្នើសុំ

២០- អាស្រ័យតាមការយល់ឃើញដូចដែលបានវែកញែកហេតុផលដូចខាងលើនេះ សូមបដិសេធចោលនូវញត្តិស្នើសុំរបស់មេធាវី៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | |

[31] សូមអាន, ឧទាហរណ៍ដូចជា រដ្ឋអាជ្ញា ទល់នឹង *Slobodan Milosevic*, សំណុំរឿងលេខ IT-02-54-AR73.6, សាលដីកាសំរេចលើ បណ្ដឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំដែលធ្វើឡើងដោយអ្នកដែលមិនមែនជាភាគីនៅក្នុងរឿងក្ដីប្រឆាំងនឹងដីកាសំរេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការបង្ហាញនិងការត្រៀមរៀបចំសំរាប់ការការពារក្ដី,ចុះថ្ងៃទី២០ មករា ២០០៤, កថាខណ្ឌទី១៩ ។